# សុន្ទរកថាឯកឧត្តម ឡុញ ហ៊ាល នាយកកម្មវិធីជាតិជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ និងជាអគ្គនាយកបច្ចេកទេសក្រសួងបរិស្ថាន

## ថ្លែងក្នុងទិវាតំបន់ដីសើមពិភពលោក

## ថ្ងៃទី២ កុម្ភៈ ឆ្នាំ ២០០៦ នៅសួនច្បារជ្រោយចង្វា-ចតុមុខ ២

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

សូមគោរព សម្តេច ទ្រង់ ឯកឧត្តម អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់!

បងប្អូនប្រជាពលរដ្ឋ ប្អូនៗនិស្សិត និងសិស្សទាំងអស់ជាទីរាប់អាន!

ជាបឋមខ្ញុំព្រះករុណា ខ្ញុំបាទសូមស្វាគមន៍ដ៏កក់ក្តៅបំផុតចំពោះការនិមន្ត យាង អញ្ជើញមកដល់ និងចូលរួមរបស់ព្រះថេរានុថេរៈ សម្តេច ទ្រង់ ឯកឧត្តម អស់លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ និងប្អូនៗ សិស្ស និស្សិតទាំងអស់ក្នុង **ទិវាតំបន់ដីសើមពិភពលោក ២ កុម្ភៈ ២០០៦ នេះ**។

ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្សណាស់សំរាប់ពិភពលោក ក្នុងការប្រារព្ធទិវាតំបន់ដីសើមពិភពលោក ជាពិសេសព្រះរាជាណាចក្រកម្ពុជា ក៏រួមចំណែកយ៉ាងផុលផុសដោយមានការចូលរួម និងគាំទ្រពីព្រះថេរានុថេរៈ សម្តេច ទ្រង់ ឯកឧត្តម អស់លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ និងប្អូនៗទាំងអស់ជាមួយពិភពលោកផងដែរដើម្បីរៀបចំនូវទិវានេះ។

តើអ្វីទៅដែលហៅថាតំបន់ដីសើម? តំបន់ដីសើមមាននៅទីណា?

តំបន់ដីសើមត្រូវបានឱ្យនិយមន័យផ្សេងៗគ្នាជាច្រើនតាមប្រទេស តាមតំបន់ និងតាមពេលវេលា តែទោះជាយ៉ាងណាក៏ដោយបណ្តាប្រទេសទាំងអស់នៅតែទទួលយកនូវនិយមន័យតំបន់ដីសើមជារួមដែល កំណត់ដោយអនុសញ្ញារ៉ាមសារ “តំបន់ដីសើមគឺជា ទីវាលទំនាបលិចទឹក ទំនាបភក់ ទីប្រកបដោយរុក្ខជាតិរលួយ ឬទឹកអាចកើតឡើងដោយធម្មជាតិ ឬសប្បនិមិត្ត មានទឹកជាអចិន្ត្រៃយ៍ ឬអនាចិន្ត្រៃយ៍ ដែលមានទឹកនឹង ឬ ហូរ ទឹកសាប ភ្លាវ ឬប្រៃ រួមទាំងតំបន់សមុទ្រ ដែលមានជំរៅទឹកមិនលើសពី ៦ម៉ែត្រនៅពេលទឹកនាច”។ ជារួមតំបន់ដែលភ្ជាប់រវាងទឹក និងដីជាតំបន់ផ្តល់នូវជីវិត រុក្ខជាតិ សត្វ និងមនុស្ស បើពិនិត្យមើលលើ

ប្រវត្តិនៃការកកើតផែនដី និងជីវវិទ្យា។ តំបន់ដីសើមជាតំបន់មួយដែលសំបូរបែបជាងគេនូវប្រភេទជីវៈចម្រុះ សត្វ រុក្ខជាតិ បើប្រៀប ធៀបទៅនិងតំបន់គោក ឬទឹក។

ព្រះរាជាណាចក្រកម្ពុជាគ្របដណ្តប់ដោយតំបន់ដីសើមច្រើនជាង៣០%នៃផ្ទៃប្រទេស ហើយដែលក្នុងនោះលើសពី២០% នៃផ្ទៃប្រទេសមានលក្ខណសំខាន់អន្តរជាតិ។ តំបន់ដីសើមសំខាន់ៗមានតាមបណ្តោយទន្លេមេគង្គ បឹងទន្លេសាប និងតំបន់ឆ្នេរ។ ទន្ទឹមនិងនោះដែរការទន្ទ្រាន និងបំផ្លាញប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមមានការកើនឡើងគួរឱ្យបារម្ភ។

កម្មវិធីជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ ជាកម្មវិធីរួមមួយដែលគ្រប់គ្រងដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) អង្គការសហភាពអភិរក្សពិភពលោក (IUCN) និងគណៈកម្មការទន្លេមេគង្គ (MRC) ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធសំខាន់ៗ។ ដោយបានទទួលការឧបត្ថម្ភពីមូលនិធិបរិស្ថានពិភពលោក (GEF) UNDP រាជរដ្ឋាភិបាលប្រទេសហូឡង់ MRC កិច្ចផ្តួចផ្តើមទឹក និងធម្មជាតិ (WANI) និងម្ចាស់ជំនួយផ្សេងទៀត កម្មវិធីនេះព្យាយាមដោះស្រាយបញ្ហាដែលមានសារៈសំខាន់បំផុតសម្រាប់ការអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវធនធានធម្មជាតិក្នុងតំបន់ដីសើមនៃអាងទន្លេមេគង្គ ជាពិសេសដើម្បីទប់ស្កាត់នូវការទន្ទ្រាននិងបំផ្លាញនូវប្រព័ន្ធអេកូឡូស៊ីទាំងនោះ។

កម្មវិធីនេះអនុវត្តដោយមានកិច្ចសហការជាមួយប្រទេសទន្លេមេគង្គខាងក្រោមទាំងបួនគឺកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម ដោយឡែកនៅកម្ពុជាកម្មវិធីនេះសហការផ្ទាល់ជាមួយក្រសួងបរិស្ថាន។ កម្មវិធីនេះបានចុះហត្ថលេខាជាផ្លូវការនៅថ្ងៃ ទី១៩ កក្កដា ឆ្នាំ២០០៤ នៅទីក្រុងវៀនច័ន្ទនៃប្រទេសឡាវ។ កម្មវិធីសង្កត់ធ្ងន់ជាយុទ្ធសាស្រ្តលើការធ្វើផែនការលើគ្រប់វិស័យ ការពង្រឹងគោលនយោបាយ និងក្របខ័ណ្ឌសេដ្ឋកិច្ច ការបង្កើនការយល់ដឹង និងពតិមាន ការលើកស្ទួយធនធានមនុស្ស បច្ចេកទេស និងនិរន្តរភាពធនធានតំបន់ដីសើមក្នុងតំបន់អនុវត្តបង្ហាញក្នុងខេត្តស្ទឹងត្រែង។

ផ្នែកមួយដ៏ធំនិងសំខាន់របស់កម្មវិធីគឺការបង្កើនការយល់ដឹងជាសាធារណអំពីតំបន់ដីសើម និងជាពិសេសគឺការចូលរួមរបស់សាធារណជន និងស្ថាប័នពាក់ព័ន្ធដើម្បីជួយការពារ និងថែរក្សាតំបន់ដីសើមរបស់យើងទាំងអស់គ្នាឱ្យមាននិរន្តរភាពសំរាប់ជាប្រយោជន៍ដល់ជាតិ និងកូនចៅជំនាន់ក្រោយ ។

សម្តេច ទ្រង់ ឯកឧត្តម អស់លោក លោកស្រី ភ្ញៀវកិត្តិយស បងប្អូនប្រជាពលរដ្ឋ និងប្អូនៗសិស្សនិស្សិតទាំងអស់!

ដូច្នេះថ្ងៃនេះ ជាថ្ងៃយុទ្ធសាស្ត្របំផុតដែលត្រូវរៀបចំជាប្រចាំឆ្នាំនូវទិវាតំបន់ដីសើមពិភពលោកនេះដែលជាស្មារតីរួមរបស់ព្រះរាជាណាចក្រកម្ពុជាដើម្បីដាស់ស្មារតីក្នុងការការពារប្រយោជន៏ធនធានតំបន់ដីសើមរបស់យើងទាំងអស់គ្នា។ ការចូលរួមថ្ងៃនេះរបស់ សម្តេច ទ្រង់ ឯកឧត្តម អស់លោក លោកស្រីគឺជាវិភាគទានមួយដ៏ធំអស្ចារ្យក្នុងកិច្ចសហប្រតិបត្តិការ សហការ និងភាពជាដៃគូរក្នុងការអភិរក្ស និងប្រើប្រាស់តំបន់ដីសើមប្រកបដោយចិរភាព។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំលើព្រះថេរានុថេរៈ សម្តេច ទ្រង់ ឯកឧត្តម អស់លោក លោកស្រី ភ្ញៀវកិត្តិយស និងប្អូនៗទាំងអស់ថា ព្រឹត្តិការណ៏ថ្ងៃនេះនឹងជាស្មារតីជាតិមួយដ៏រឹងមាំ យូរអង្វែង និងទូលំទូលាយក្នុងការអភិរក្សតំបន់ដីសើមរបស់យើងអោយមាននិរន្តរភាព!

**ចំពោះមុខនៃភាពក្រីក្រ...តំបន់ដីសើមជាទីពឹងអាស្រ័យ!**

**ជយោ! ស្មារតីទិវាតំបន់ដីសើមពិភពលោក ២ កុម្ភៈ ២០០៦**